ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**
**គណៈកម្មការផ្តល់ភាពស្របច្បាប់ដល់ពលករកម្ពុជា**
**ដែលកំពុងស្នាក់នៅ និងធ្វើការនៅប្រទេសថៃ**

# សេចក្តីប្រកាសព័ត៌មាន

នារសៀលថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០១៧ នៅទីស្តីការក្រសួងការងារថៃ **ឯកឧត្តម អ៊ិត សំហេង** រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងជាប្រធានគណៈកម្មការផ្តល់ភាពស្របច្បាប់ដល់ពលករកម្ពុជាដែលកំពុងស្នាក់នៅ និងធ្វើការនៅប្រទេសថៃ បានដឹកនាំប្រតិភូកម្ពុជាជួបប្រជុំជាមួយ **ឯកឧត្តម ស៊ីរីឆៃ ឌីស្តាគុល** (Sirichai Distakul) រដ្ឋមន្ត្រីក្រសួងការងារថៃ ដើម្បីពិភាក្សាលើកិច្ចសហប្រតិបត្តិការក្នុងការគ្រប់គ្រងកម្លាំងពលកម្ម ជាពិសេសការស្វែងរកដំណោះស្រាយក្នុងការផ្តល់ភាពស្របច្បាប់ជូនពលករកម្ពុជា ដែលបានកំពុងស្នាក់នៅ និងធ្វើការនៅប្រទេសថៃ។ កិច្ចប្រជុំនេះបានប្រព្រឹត្តទៅក្រោមបរិយាកាសយោគយល់ ស្និទ្ធស្នាល និងទទួលបានលទ្ធផលជាវិជ្ជមានដូចខាងក្រោម៖

១. រាជរដ្ឋាភិបាលថៃមិនអនុវត្តទោសពិន័យចំពោះនិយោជកថៃ ដែលកំពុងប្រើប្រាស់កម្លាំងពលករកម្ពុជា ដែលគ្មានឯកសារនោះទេ ហើយរាជរដ្ឋាភិបាលថៃក៏មិនបណ្តេញពលករកម្ពុជា ដែលបានចូលដល់ក្នុងទឹកដីថៃ ហើយកំពុងធ្វើការជាមួយក្រុមហ៊ុន ឬរោងចក្រណាមួយនៅក្នុងប្រទេសថៃនោះដែរ។ ក្រសួងការងារថៃនឹងផ្តល់ឱកាសចំនួន ១៥ថ្ងៃ (ចាប់ពីថ្ងៃទី២៤ ខែកក្កដា ដល់ថ្ងៃទី៧ ខែសីហា ឆ្នាំ២០១៧) ដល់ពលករកម្ពុជា និងនិយោជកថៃ ដែលមិនទាន់មានឯកសារអ្វីទាំងអស់ឱ្យទៅចុះឈ្មោះនៅតាមការិយាល័យចុះបញ្ជីពលករបរទេស។ ក្រសួងការងារថៃនឹងបើកការិយាល័យចុះឈ្មោះពលករបរទេសចំនួន ១០កន្លែង នៅក្នុងទីក្រុងបាងកក និងចំនួន ១កន្លែង នៅក្នុងខេត្តនីមួយៗនៃប្រទេសថៃ។

២. ក្រសួងការងារថៃបានឯកភាពតាមការស្នើសុំរបស់ភាគីកម្ពុជា ដោយអនុញ្ញាតដល់ពលករកម្ពុជា ដែលមានលិខិតឆ្លងដែន/លិខិតធ្វើដំណើរ ឬប័ណ្ណពណ៌ស៊ីជម្ពូស្របច្បាប់ពេលដំបូង ប៉ុន្តែក្រោយមកបានផ្លាស់ប្តូរនិយោជកដោយខុសនីតិវិធី ហើយក្លាយទៅជាពលករខុសច្បាប់ អាចមកចុះបញ្ជីជាមួយមន្ទីរការងារថៃ ដើម្បីបំពេញឯកសារ ដើម្បីក្លាយទៅជាពលករស្របច្បាប់វិញ។

៣. ភាគីថៃបានឯកភាពតាមសំណើរបស់កម្ពុជាក្នុងការរៀបចំ យុទ្ធនាការ១០០ថ្ងៃ បើកផ្តល់លិខិតឆ្លងដែន/លិខិតធ្វើដំណើរ និងប័ណ្ណOCWC ដល់ពលករកម្ពុជាឱ្យបានចំនួន ១៦ម៉ឺននាក់ ដែលបានធ្វើការបញ្ជាក់អត្តសញ្ញាណជាមួយគណៈកម្មការផ្តល់ភាពស្របច្បាប់រួចហើយនាពេលកន្លងមក ទោះបីជាពលករបានធ្វើការផ្លាស់ប្តូរនិយោជក ឬក្រុមហ៊ុនខុសពីក្នុងឯកសារដើមក៏ដោយ។ យុទ្ធនាការនេះនឹងចាប់ផ្តើមពីថ្ងៃទី០១ ខែសីហា ឆ្នាំ២០១៧នេះ ដោយគណៈកម្មការនឹងបញ្ជូនក្រុមចល័តចំនួន ៤ក្រុម បន្ថែមទៀត ដើម្បីចុះបើកផ្តល់តាមរោងចក្រធំៗទាំង ២០០រោងចក្រ ដែលមានប្រើប្រាស់ពលករកម្ពុជាលើសពី ៧០នាក់។ កម្រៃសេវាផ្លូវការក្នុងការបើកផ្តល់សំណុំឯកសារ ដែលភាគីថៃនិងកម្ពុជាបានឯកភាពគ្នាគឺ ៩៥០បាត។

៤. ភាគីថៃក៏បានឯកភាពតាមសំណើរបស់កម្ពុជាក្នុងការរៀបចំ យុទ្ធនការ១ទៀតគឺ យុទ្ធនាការបញ្ជាក់អត្តសញ្ញាណពលករកម្ពុជា ដែលមិនទាន់មាន លិខិតធ្វើដំណើរ និងប័ណ្ណ OCWC ដើម្បីយកទៅសុំភាពស្របច្បាប់ពីអាជ្ញាធរថៃ ដោយកំណត់យន្តការបញ្ជាក់អត្តសញ្ញាណពលករ និងបើកផ្តល់ឯកសារ ជូនពលករនៅក្នុងថ្ងៃតែមួយ ហើយពលករអាចទៅសុំទិដ្ឋាការស្នាក់នៅ (Stay Permit) និងទិដ្ឋាការការងារ (Work Permit) ពីភាគីថៃនៅកន្លែងតែមួយតែម្តង។ យុទ្ធនាការនេះនឹងចាប់ផ្តើមក្នុងសប្តាហ៍ទី១ នៃខែសីហា ឆ្នាំ២០១៧ ដោយមានក្រុមការងារចំនួន ២០ក្រុម បន្ថែមទៀត ហើយផ្តើមចេញពីពលករផ្នែកនេសាទក្នុងខេត្តរ៉ាក់យ៉ង និងផ្នែក ឬខេត្តផ្សេងទៀតជាបន្តបន្ទាប់។ កម្រៃសេវាផ្លូវការក្នុងការធ្វើ និងបើកផ្តល់សំណុំឯកសារក្នុងថ្ងៃតែមួយ ដែលភាគីថៃ និងកម្ពុជាបានឯកភាពគ្នាគឺ ២៣៥០បាត។

អាស្រ័យន័យដូចបានជម្រាបជូនខាងលើ សូមសាធារណជន ជាពិសេសពលករកម្ពុជាដែលកំពុងស្នាក់នៅ និងធ្វើការនៅប្រទេសថៃ ជ្រាបជាព័ត៌មាន និងរក្សាភាពហ្នឹងហ្នរក្នុងការបំពេញការងារជាប្រក្រតី ជាមួយនិយោជករបស់ខ្លួន។ គណៈកម្មការផ្តល់ភាពស្របច្បាប់ នឹងចុះទៅផ្តល់សំណុំឯកសាផ្តល់ភាពស្របច្បាប់ជូនបងប្អូនពលករនៅក្នុងទឹកដីថៃតែម្តង។ ដោយឡែកប្រជាពលរដ្ឋ ដែលកំពុងស្នាក់នៅកម្ពុជា ហើយមានបំណងចេញទៅធ្វើការងារនៅប្រទេសថៃ សូមជ្រើសរើសការចេញទៅដោយស្របច្បាប់ជាពលករ (MOU) តាមរយៈភ្នាក់ងារជ្រើសរើសឯកជនស្របច្បាប់ទាំង៧៧ ដែលមានការទទួលស្គាល់ដោយអាជ្ញាធរកម្ពុជា និងថៃ។

*រាជធានីភ្នំពេញ ថ្ងៃទី០៧ ខែកក្កដា ឆ្នាំ២០១៧*